# ទសរថជាតក

(រឿងព្រះរាម និងព្រះនាងសីតា)



## ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា

## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**ឃួយ ទ៉ាន់ថន**

**ព.ស. ២៥៦០**

# ទសរថជាតក

## (រឿងព្រះរាម និង ព្រះនាងសីតា)

*រៀបរៀងដោយ*

**ហួយ វ៉ាន់ថន**

សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**ព.ស. ២៥៦៣**

| | |
|---|---|
| ឈ្មោះសៀវភៅ | **ទសរថជាតក** |
| រៀបរៀងដោយ | ហួយ វ៉ាន់ថន |
| | បុគ្គលិកពុទ្ធិកបណ្ឌិត<br>សភានៃសាកលវិទ្យា<br>ល័យបញ្ញាសាស្ត្រកម្ពុជា |
| ទីតាំងធ្វើ | ពុទ្ធិកបណ្ឌិតសភា |
| ការផ្សាយ | របស់ពុទ្ធិកបណ្ឌិតសភា |
| រក្សាសិទ្ធិ | ពុទ្ធិកបណ្ឌិតសភា |
| កាលបរិច្ឆេទ | ព.ស. ២៥៦០ |
| សម្រាប់ | ធម្មទាន |

# ទសរថជាតក

## (រឿងព្រះរាម និង ព្រះនាងសីតា)

ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតវ័ន ទ្រង់ប្រារព្ធកុដុម្ពិកៈ[១]ដែលមានបិតាស្លាប់មួយរូប បានត្រាស់ធម្មទេសនានេះ មានពាក្យថា **ឯថ លក្ខណា សីតា ច** ដូច្នេះជាដើម។

## បច្ចុប្បន្ននិទាន

សេចក្ដីពិស្ដារថា កុដុម្ពិកៈនោះ កាលបិតាធ្វើកាលកិរិយាហើយ ត្រូវសេចក្ដីសោកគ្របសង្កត់ ទើប

---

[១]· កុដុម្ពិកៈ ( <u>ន.</u> ) [--ក.] ( បា. ) អ្នកមានសម្បត្តិដោយផលប្រយោជន៍កើតអំពីស្រែចម្ការច្បារដំណាំ ។ សំដីនិយាយច្រើនក្លាយមកជា ក្ដុម្ពី ។

បោះបង់កិច្ចទាំងពួង បណ្ដោយទៅតាមសេចក្ដី
សោកសៅ ។ ព្រះសាស្ដាប្រមើលមើលសត្វលោក ក្នុង
បច្ចូសសម័យ ( ក្នុងវេលាជិតភ្លឺ ) ទតឃើញ
ឧបនិស្ស័យសោតាបត្តិផលរបស់កុដុម្ពិក:នោះ ។ ព្រឹក
ឡើងស្ដេចត្រាច់ទៅបិណ្ឌបាត្រក្នុងក្រុងសាវត្ថី សោយ
ក្រយាហារស្រេចហើយ ទ្រង់បញ្ជូនភិក្ខុទាំងឡាយឲ្យ
ត្រឡប់ ទ្រង់កាន់យកសមណបច្ឆាមួយរូបយាងទៅ
កាន់ផ្ទះរបស់កុដុម្ពិក:នោះ ។ កាលព្រះសាស្ដាត្រាស់
ហៅកុដុម្ពិក:ដែលថ្វាយបង្គំហើយអង្គុយចុះ ដោយ
ពាក្យដ៏ពីរោះ ទើបត្រាស់ថា **កឹំ សោចសិ ឧបាសក**
ម្នាលឧបាសក អ្នកសោយសោកព្រោះអ្វី? កាលកុដុម្ពី
ទូលថា **អាម, ភន្តេ, បិតុសោកោ មំ ពាធតិ** ព្រះ
ករុណា ព្រះអង្គដ៏ចម្រើន ! សេចក្ដីសោកព្រោះបិតា

ស្តាប់កំពុងបៀតបៀនខ្ញុំព្រះករុណា។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក បណ្ឌិតក្នុងកាលមុនបានដឹងលោកធម៌ ៨ ប្រការតាមសេចក្តីពិត កាលបិតាធ្វើកាលកិរិយាហើយ ក៏មិនប្រសព្វសេចក្តីសោក សូម្បីបន្តិចបន្តួចឡើយ។ កុដុម្ពិកៈក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា ៖

## អតីតនិទាន

**អតីតេ ពារាណសិយំ ទសរថមហារាជា ជាម** ក្នុងអតីតកាល ព្រះរាជាព្រះនាម ទសរថមហារាជ ទ្រង់លះបង់នូវអគតិធម៌ សោយរាជសម្បត្តិប្រកបដោយធម៌ ក្នុងនគរពារាណសី ។ ព្រះអគ្គមហេសីដែលជាធំជាងស្ត្រី ១៦,០០០ របស់ព្រះបាទទសរថមហារាជនោះ ប្រសូតព្រះឱរស ២ ព្រះអង្គ ព្រះធីតា

(រឿងព្រះរាម និងព្រះនាងសីតា)

១ ព្រះអង្គ ។ ព្រះឱរសច្បងព្រះនាមថា **រាមបណ្ឌិត** ព្រះឱរសទីពីរ ព្រះនាមថា **លក្ខណកុមារ** ព្រះធីតាព្រះនាមថា **សីតាទេវី**[១] ។

ក្នុងកាលបន្តបន្ទាប់មកទៀត ព្រះអគ្គមហេសីទ្រង់សោយព្រះពិលាល័យ ( ព្រះអគ្គមហេសីអស់ព្រះជន្ម ) ។ ព្រះរាជាមានសេចក្ដីសោកអស់កាលដ៏យូរ ព្រោះការសោយព្រះពិលាល័យនៃព្រះអគ្គមហេសីនោះ។ ពួកអាមាត្យនាំគ្នាក្រាបទូលឲ្យទ្រង់ស្រាកស្រាន្ត

---

១. ព្រះនាងសីតាទេវីហ្នឹងហើយ ដែលព្រះនាងមទ្រីលើកឡើងសម្ដែងថា ខ្ញុំជាភរិយារបស់ព្រះរាជបុត្រដ៏មានសិរីដែលគេនិរទេស ខ្ញុំមិនហ៊ានមើលងាយព្រះរាជស្វាមីនោះ ដូចនាងសីតាជាស្ត្រីមានវ័ត មិនហ៊ានមើលងាយព្រះរាម ។ ( វេស្សន្តរជាតក មទ្ទីបព្វ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក មហានិបាត បិដកលេខ ៦៣ ទំព័រ ១៧៨ ) ។

ទ្រង់ធ្វើការបរិហារដែលគប្បីធ្វើដល់ព្រះនាង ហើយ
ទ្រង់តាំងស្ត្រីដទៃទុកក្នុងតំណែងជាអគ្គមហេសី ។
ព្រះអគ្គមហេសីថ្មីនោះជាស្រឡាញ់ ជាទីគាប់ព្រះ
ហឫទ័យនៃព្រះរាជា ។ ក្នុងកាលជាខាងក្រោយមក
សូម្បីព្រះអគ្គមហេសីទីពីរនោះក៏ទ្រង់គភ៌ ទ្រង់បាន
ទទួលព្រះរាជទានគ្រឿងរក្សាគភ៌ ហើយប្រសូតនូវ
ព្រះឱរស។ ព្រះញាតិវង្សាបានដាក់ព្រះនាមរបស់ព្រះ
ឱរសនោះថា **ភរតកុមារ** ។ ព្រះបាទទសរថត្រាស់ថា
ម្នាលនាងដ៏ចម្រើន យើងឲ្យពរដល់នាង នាងចូរ
ទទួលពរចុះ ដោយទ្រង់ស្រឡាញ់ក្នុងព្រះឱរស ។
ព្រះនាងទទួលពរនោះទុក។ ក្នុងពេលដែលព្រះភរត-
កុមារមានព្រះជន្ម ៧-៨ វស្សា ទើបចូលទៅគាល់ព្រះ
រាជាក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះអង្គបាន

ព្រះរាជទានពរដល់បុត្ររបស់ខ្ញុំម្ចាស់ ឥឡូវនេះ សូមទ្រង់ព្រះករុណាមេត្តាព្រះរាជទានពរនោះដល់បុត្ររបស់ខ្ញុំម្ចាស់។ ព្រះបាទទសរថត្រាស់ថា ម្នាលនាងដ៏ចម្រើន ចូរទទួលចុះ។ ព្រះនាងទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ព្រះរាជទានរាជ-សម្បត្តិដល់បុត្ររបស់ខ្ញុំម្ចាស់ ។ ព្រះរាជាទ្រង់ទះព្រះហស្តត្រាស់គំរាមថា នែស្រីថោកទាប នាងចូរវិនាសទៅ បុត្រទាំង ២ របស់យើង រមែងរុងរឿងបីដូចជាគំនរភ្លើង នាងនឹងឲ្យយើងសម្លាប់បុត្រទាំង ២ ហើយ សូមរាជសម្បត្តិឲ្យបុត្ររបស់នាងឬ ។ ព្រះអគ្គ-មហេសីភិតភ័យហើយចូលកាន់ដំណាក់ដ៏មានសិរី ។ សូម្បីក្នុងថ្ងៃដទៃ ៗ ក៏គង់ទូលសុំរាជសម្បត្តិប៉ុណ្ណោះនឹងព្រះរាជារឿយ ៗ ។ ព្រះរាជាគ្រាមិនប្រទានដល់

ព្រះនាង ទើបទ្រង់ត្រិះរិះថា ឈ្មោះថាមាតុគ្រាម ជាមនុស្សអកតញ្ញូ ទ្រុស្តមិត្ត នាងនេះនឹងក្លែងសារ ឬជួលឲ្យគេសម្លាប់បុត្រទាំង ២ របស់យើង ។ ព្រះអង្គទើបត្រាស់ឲ្យហៅព្រះឱរសទាំង ២ ចូលគាល់ ទ្រង់ប្រាប់រឿងនោះ មានព្រះតម្រាស់ថា ម្នាលបុត្រ អន្តរាយគង់នឹងមានដល់អ្នកដែលនៅក្នុងទីនេះ អ្នកចូរនាំគ្នាទៅកាន់ដែននៃសាមន្តរដ្ឋ ឬព្រៃ ហើយត្រឡប់មកវិញក្នុងពេលដែលបិតាចូលទិវង្គត គប្បីកាន់យករាជសម្បត្តិរបស់ត្រកូលចុះ ដូចនេះហើយត្រាស់បញ្ជាឲ្យពួកព្រាហ្មណ៍ចូលគាល់ និងត្រាស់សួរការកំណត់ព្រះជន្មាយុរបស់ព្រះអង្គ ទ្រង់ស្តាប់ថា នឹងប្រព្រឹត្តទៅដល់ ១២ ឆ្នាំខាងមុខ ទើបត្រាស់ថា ម្នាលបុត្រ កន្លងទៅ ១២ ឆ្នាំអំពីនេះទៅ ពួកអ្នកចូរនាំគ្នា

មកឲ្យមហាជនលើកស្វេតច្ឆត្រថ្វាយចុះ ។ ព្រះឱរស ទាំងនោះក្រាបទូលថា ល្អ ហើយនាំគ្នាថ្វាយបង្គំព្រះ បិតា ទ្រង់ព្រះកន្សែង រួចស្តេចចេញចាកប្រាសាទ ព្រះ នាងសីតាទេវីទ្រង់ព្រះតម្រិះថា សូម្បីយើងក៏នឹងទៅ ជាមួយព្រះម្ចាស់បង ព្រះនាងថ្វាយបង្គំព្រះបិតា ហើយទ្រង់ព្រះកន្សែងស្តេចចេញទៅ ។ ក្សត្រទាំង ៣ ព្រះអង្គឡោមព័ទ្ធចោមរោមដោយមហាជនចេញចាក ព្រះនគរ ទ្រង់ឲ្យមហាជននាំគ្នាត្រឡប់ ស្តេចចូលកាន់ ហិមវន្តប្រទេសតាមលំដាប់ សាងអាស្រមក្នុងប្រទេស ដែលមានទឹកនិងមូលផលាផលច្រើន ទ្រង់ចិញ្ចឹមជីវិត ដោយផលាផល អាស្រ័យនៅហើយក្នុងទីនោះ ។

ព្រះលក្ខណបណ្ឌិត និងព្រះនាងសីតា បាន ទូលសុំព្រះរាមបណ្ឌិត ហើយទទួលប្តេជ្ញាថា សូមព្រះ

អង្គតាំងនៅក្នុងឋានៈជាព្រះបិតារបស់យើងខ្ញុំព្រះអង្គ ហេតុនោះ សូមទ្រង់ប្រថាប់នៅក្នុងអាស្រមប៉ុណ្ណោះ យើងខ្ញុំនឹងនាំផលាផលទំនុកបម្រុងព្រះអង្គ ។ ចាប់អំពីនោះមក ព្រះរាមគង់នៅជាប្រចាំក្នុងអាស្រមប៉ុណ្ណោះ ។ ព្រះលក្ខណ៍ និងព្រះនាងសីតាទាំង ២ នាំគ្នាស្វែងរកផលាផលមកទំនុកបម្រុងព្រះរាម ។ កាលក្សត្រទាំង ៣ អង្គនោះចិញ្ចឹមជីវិតដោយផលាផលយ៉ាងនេះ ព្រះបាទទសរថមហារាជ ស្តេចសោយទិវង្គតក្នុងឆ្នាំទី ៩ ដោយសេចក្តីសោកសៅព្រោះព្រាត់ប្រាសព្រះឱរស ។ ព្រះទេវីធ្វើសរីរកិច្ច (ថ្វាយព្រះភ្លើង ) ដល់ព្រះរាជសពនោះហើយ ទ្រង់ត្រាស់ថា សូមពួកលោកចូរថ្វាយស្វេតច្ឆត្រដល់ភរតកុមារ ដែលជាបុត្រយើង។ តែពួកអាមាត្យទូលថា ម្ចាស់ស្វេតច្ឆត្រ

នេះនៅក្នុងព្រៃ ដូចនេះហើយទើបមិនព្រមថ្វាយ ។ ព្រះភរតៈត្រាស់ថា "យើងនឹងនាំព្រះរាម ដែលជាព្រះភាតារបស់យើងមកអំពីព្រៃ នឹងឲ្យទ្រង់លើកនូវស្វេតច្ឆត្រ ឡើងសោយរាជ្យ" ទ្រង់កាន់បញ្ចរាជកកុធភណ្ឌ ៥ [១] ព្រមដោយសេនាទាំង ៤ ចូលទៅព្រៃដើម្បីរកព្រះរាម រហូតដល់ទីប្រថាប់ ឲ្យតាំងបន្ទាយក្នុងទីមិនឆ្ងាយ ស្ដេចចូលទៅកាន់អាស្រមជាមួយអាមាត្យ ២-៣ នាក់

---

១. **បញ្ចរាជកកុធភណ្ឌ** ( គ្រឿងប្រដាប់របស់ព្រះរាជាសម្រាប់សោយរាជ្យ ) ៥ យ៉ាង គឺ ៖

១. **ខគ្គៈ** ព្រះខ័ន។

២. **ឆត្តៈ** ឆត្រ ( សំដៅដល់ សេតឆត្ត = ឆត្រស )។

៣. **ឧណ្ហិសៈ** មកុដ ។

៤. **ចាទុកា** ស្បែកជើង ( សំដៅដល់ សុវណ្ណបាទុកា = ស្បែកជើងមាស )។

៥. **វាលពីជនី** ផ្លិតរោមសត្វ ។

( ចាកគម្ពីរអភិធានប្បទីបិកាគាថាទី ៣៥៨ )

ក្នុងវេលាដែលព្រះលក្ខណ៍ និងព្រះនាងសីតាយាង ទៅព្រៃ ព្រះអង្គចូលទៅគាល់ព្រះរាមអ្នកប្រាសចាក សេចក្ដីសង្ស័យ ប្រថាប់គង់ជាសុខ ហាក់បីដូចជា រូបបដិមាមាសដែលតាំងទុកជិតទ្វារអាស្រម ថ្វាយបង្គំ ហើយឋិតនៅក្នុងទីសមគួរមួយ ក្រាបទូលការប្រព្រឹត្ត ទៅរបស់ព្រះរាជបិតា ហើយក៏ដួលចុះជិតព្រះបាទ ( របស់ព្រះរាម ) ទ្រង់ព្រះកន្សែងមួយអន្ទើដោយពួក អាមាត្យ ។

ព្រះរាមទ្រង់មិនសោយសោក មិនបានព្រះ កន្សែងឡើយ ។ សូម្បីអាការៈខុសប្រក្រតីនៃឥន្ទ្រិយ ក៏ មិនមានដល់ព្រះអង្គដែរ ។ ក្នុងវេលាដែលព្រះភរតៈ ប្រថាប់គង់ព្រះកន្សែងនោះ ជាវេលាសាយណ្ហសម័យ ព្រះលក្ខណ៍ និងព្រះនាងសីតាទាំង ២ ព្រះអង្គ ទ្រង់

នាំគ្នាកាន់ផលាផលយាងមកដល់ ។ ព្រះរាមត្រិះរិះថា ប្អូនលក្ខណ៍ និងនាងសីតានៅក្មេងខ្ចី មិនមានប្រាជ្ញាកំណាត់ពិចារណាដូចយើង បើទទួលដំណឹងថា បិតារបស់ខ្លួនសោយទិវង្គតដោយរហ័សយ៉ាងនេះ កាលមិនអាចនឹងទប់ទល់សេចក្ដីសោកបាន បេះដូងរបស់គេក៏អាចនឹងបែក យើងត្រូវធ្វើឧបាយឲ្យប្អូនលក្ខណ៍ និងនាងសីតាចូលទៅត្រាំទឹក ហើយយើងនឹងប្រាប់ដំណឹងនោះ ។

លំដាប់នោះ ព្រះរាមចង្អុលបង្ហាញឧទកដ្ឋានមួយ ដែលនៅខាងមុខក្សត្រទាំង ២ ទើបត្រាស់ថា អ្នកទាំង ២ ត្រឡប់មកយូរណាស់ នេះជាទណ្ឌកម្មរបស់អ្នក អ្នកចូរចុះទៅត្រាំទឹក ហើយបិតនៅ ដូចនេះហើយ ទើបត្រាស់កន្ទុះគាថាថា ៖

ឯថ លក្ខណា សីតា ច, ឧភោ ឱតរថោទកំ។

ម្នាលលក្ខណៈ និងនាងសីតា អ្នកទាំងឡាយចូរមក អ្នកទាំង ២ នាក់ចូរចុះទឹក ។

ព្រះលក្ខណៈ និងព្រះនាងសីតាទាំង ២ ព្រះអង្គនោះ នាំគ្នាទៅឈរ ( ក្នុងទឹក ) ដោយព្រះតម្រាស់មួយគ្រាប៉ុណ្ណោះ ។ ពេលនោះ ព្រះរាមកាលនឹងប្រាប់ដំណឹងព្រះបិតាដល់ក្សត្រទាំង ២ ទើបត្រាស់កន្លះគាថាដ៏សេសថា ៖

ឯវាយំ ភរតោ អាហ, រាជា ទសរថោ មតោ។

ភរតកុមារ បាននិយាយយ៉ាងនេះថា ព្រះបាទទសរថទ្រង់ទិវង្គតហើយ ។

ព្រះលក្ខណ៍ និងព្រះនាងសីតាទាំង ២ បាន ស្ដាប់ដំណឹងថា ព្រះរាជបិតាសោយទិវង្គតប៉ុណ្ណោះ ក៏ ដល់វិសញ្ញិភាព ( សន្ទប់បាត់ទៅ ) ។ ( ពេលភ្ញាក់ដឹង ខ្លួនឡើង ) ព្រះរាមត្រាស់ប្រាប់ម្ដងទៀត ព្រះលក្ខណ៍ និងព្រះនាងសីតានោះ ក៏សន្ទប់ម្ដងទៀត ។ ពួក អាមាត្យជួយលើកក្សត្រទាំង ២ ដែលទ្រង់ដល់វិសញ្ញី ដរាបដល់គ្រាទី ៣ ដោយអាការៈនេះ ចេញចាកទឹក ឲ្យបិតនៅលើដី ។ កាលក្សត្រទាំង ២ បានខ្យល់ អស្សាសបស្សាសៈហើយ គ្រប់អង្គនាំគ្នាអង្គុយព្រះ កន្សែងសោយសោករឿយ ៗ ។ គ្រានោះ ព្រះភរតៈ ទ្រង់ត្រិះរិះថា ព្រះភាតារបស់យើងលក្ខណកុមារ និង ព្រះភគិនីសីតាទេវីស្ដាប់ដំណឹងថា ព្រះបាទទសរថ សោយទិវង្គត មិនអាចទប់ទល់សេចក្ដីសោកបាន តែ

ព្រះរាមទ្រង់មិនបានសោយសោក មិនបានគ្រាំគ្រា ឡើយ អ្វីហ្ន៎ ជាហេតុនៃសេចក្តីមិនសោករបស់ព្រះអង្គ ត្រូវសួរព្រះអង្គមើល ។ កាលព្រះភរតៈនឹងត្រាស់សួរ ទើបពោលគាថាទី ២ ថា ៖

**កេន រាមប្បភាវេន, សោចិតព្វំ ន សោចសិ;**

**បិតរំ កាលកតំ សុត្វា, ន តំ បសហតេ ទុខំ។**

បពិត្រព្រះរាម ដោយអានុភាពអ្វី ទើបទ្រង់បាន ឮថា ព្រះបិតាទិវង្គតហើយ មិនសោកស្តាយ របស់ ដែលគួរសោកស្តាយ សេចក្តីទុក្ខមិនគ្របសង្កត់ទ្រង់ ។

លំដាប់នោះ ព្រះរាមបណ្ឌិត កាលនឹងសម្តែង ហេតុដែលរារាំងមិនឲ្យព្រះអង្គសោយសោកដល់ព្រះ ភរតៈ ទើបត្រាស់ថា ៖

យំ ន សក្កា និបាលេតុំ, បោសេន លបតំ ពហុំ;
ស កិស្ស វិញ្ញូ មេធាវី, អត្តានមុបតាបយេ។

ជីវិតណា ( របស់ពួកសត្វ ) បណ្តាពួកបុរស ដែលរវើរវាយ បុរស ( សូម្បីតែម្នាក់ ) ក៏មិនអាចដើម្បីរក្សាជីវិតច្រើននោះបានទេ វិញ្ញូជនជាមេធាវីនោះ ធ្វើខ្លួនឲ្យក្តៅក្រហាយ ដើម្បីអ្វី ។

ទហរា ច ហិ វុឌ្ឍា ច, យេ ពាលា យេ ច បណ្ឌិតា;
អឌ្ឍា ចេវ ទលិទ្ទា ច, សព្វេ មច្ចុបរាយណា។

សេចក្តីពិតថា ជនទាំងឡាយណា ទាំងក្មេង ទាំងចាស់ ទាំងល្ងង់ ទាំងប្រាជ្ញ ទាំងអ្នកមាន ទាំងអ្នកក្រ ជនទាំងអស់នោះ សុទ្ធតែមានសេចក្តីស្លាប់ នៅខាងមុខ ។

ផលានមិវ បក្កានំ, និច្ចំ បតនតោ ភយំ;

ឯវំ ជាតាន មច្ចានំ, និច្ចំ មរណតោ ភយំ។

ផ្លែឈើទុំទាំងឡាយ មានសេចក្តីខ្លាច អំពីកិរិយាជ្រុះជានិច្ច យ៉ាងណាមិញ ពួកសត្វកើតហើយ ក៏មានសេចក្តីខ្លាច អំពីសេចក្តីស្លាប់ជានិច្ច យ៉ាងនោះដែរ ។

សាយមេកេ ន ទិស្សន្តិ, បាតោ ទិដ្ឋា ពហុជ្ជនា;

បាតោ ឯកេ ន ទិស្សន្តិ, សាយំ ទិដ្ឋា ពហុជ្ជនា។

ជនទាំងឡាយច្រើនពួកខ្លះ គេឃើញក្នុងវេលាព្រឹក វេលាល្ងាចមិនឃើញ ជនទាំងឡាយច្រើនពួកខ្លះ គេឃើញក្នុងវេលាល្ងាច វេលាព្រឹកមិនឃើញ ។

បរិទេវយមានោ ចេ, កិញ្ចិទត្ថំ ឧទព្ពហេ;

សម្ភគ្គោ ហិំសមត្តានំ, កាយិក តំ វិចក្ខណោ។

បើបុគ្គលអ្នកវង្វេង កាលខ្សឹកខ្សួល បៀតបៀនខ្លួន ហើយគប្បីនាំមកនូវប្រយោជន៍បន្តិចបន្តួចបាន អ្នកប្រាជ្ញ ក៏គប្បីធ្វើសេចក្តីខ្សឹកខ្សួលនោះដែរ ។

កិសោ វិវណ្ណោ ភវតិ, ហិំសមត្តានមត្តនោ;

ន តេន បេតា ចាលេន្តិ, និរត្ថា បរិទេវនា។

( បុគ្គលខ្សឹកខ្សួល ) បៀតបៀនខ្លួនរបស់ខ្លួន ជាអ្នកស្គម មិនមានពណ៌សម្បុរ ពួកសត្វដែលទៅកាន់បរលោក មិនមែនញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយសេចក្តីខ្សឹកខ្សួលនោះឡើយ ព្រោះថា សេចក្តីខ្សឹកខ្សួល មិនមានប្រយោជន៍ទេ ។

យថា សរណមាទិត្តំ, វារិនា បរិនិព្ពយេ;

ឯវម្បិ ធីរោ សុតវា, មេធាវី បណ្ឌិតោ នរោ;

ខិប្បមុប្បតិតំ សោកំ, វាតោ តូលំវ ធំសយេ។

*( បណ្ឌិតបុរស ) គប្បីញ៉ាំងផ្ទះដែលភ្លើងឆេះឲ្យរលត់ ដោយទឹកបានយ៉ាងណាមិញ ធីរជន ជាមេធាវីបណ្ឌិត បានស្តាប់ហើយ គប្បីញ៉ាំងសេចក្តីសោក ដែលកើតហើយឲ្យរលត់ឆាប់ ដូចខ្យល់បក់ផាត់នូវប៉ុយ យ៉ាងនោះដែរ ។*

មច្ចោ ឯកោវ អច្ចេតិ, ឯកោវ ជាយតេ កុលេ;

សំយោគបរមាត្វេវ, សម្ភោគា សព្វបាណិនំ។

*សត្វរមែងទៅកាន់បរលោកតែម្នាក់ឯង កើតក្នុងត្រកូលក៏តែម្នាក់ឯង ការសេពគប់នៃពួកសត្វទាំងអស់ គឺមានការជួបជុំ ជាការប្រសើរបំផុត ។*

តស្មា ហិ ធីរស្ស ពហុស្សុតស្ស,
សម្បស្សតោ លោកមិមំ បរញ្ច;

អញ្ញាយ ធម្មំ ហទយំ មនញ្ច,
សោកា មហន្តាបិ ន តាបយន្តិ។

*ព្រោះហេតុនោះ សេចក្ដីសោកទាំងឡាយ សូម្បីធំ ក៏មិនដុតកម្ដៅនូវហទយវត្ថុ និងចិត្តរបស់អ្នកប្រាជ្ញជាពហុស្សូត ដែលឃើញច្បាស់នូវលោកនេះ និងលោកខាងមុខ ព្រោះដឹងច្បាស់នូវធម៌ ។*

សោហំ ទស្សញ្ច ភោក្ខញ្ច, ភរិស្សាមិ ច ញាតកេ;

សេសញ្ច បាលយិស្សាមិ, កិច្ចមេតំ វិជានតោ។

យើងនោះ នឹងរក្សានូវយសផង ភោគៈផង ភរិយាទាំងឡាយផង ញាតិទាំងឡាយផង និងជនដ៏វិសេសផង នេះជាកិច្ចរបស់អ្នកប្រាជ្ញ ។

ព្រះរាមបានប្រកាសនូវអនិច្ចតាធម៌ ដោយគាថាទាំងឡាយ ១០ នេះ។

ពួកជនស្តាប់ធម្មទេសនា ដែលប្រកាសសេចក្តីមិនទៀង របស់ព្រះរាមហើយ ក៏មានចិត្តធូរស្រាល ។ បន្ទាប់មក ព្រះភរតៈថ្វាយបង្គំព្រះរាម ហើយទូលថា សូមព្រះអង្គទទួលរាជសម្បត្តិ ក្នុងនគរពារាណសី ។ ព្រះរាមត្រាស់ថា ម្នាលប្អូន អ្នកចូរនាំព្រះលក្ខណ៍ និងនាងសីតាទៅគ្រប់គ្រងរាជសម្បត្តិចុះ ។ ព្រះភរតៈទូលថា ព្រះអង្គប៉ុណ្ណោះជាអ្នកគ្រងរាជសម្បត្តិ ។ ព្រះរាមត្រាស់ថា ម្នាលប្អូន ព្រះបិតារបស់យើងបានត្រាស់ទុក

នឹងបងថា តទៅដោយកន្លង ១២ ឆ្នាំ អ្នកចូរមកគ្រង
រាជសម្បត្តិ កាលបងទៅក្នុងកាលឥឡូវនេះ ក៏ឈ្មោះ
ថា មិនធ្វើតាមព្រះតម្រាស់របស់ព្រះអង្គ តែក្នុងកាល
ផុតអំពី ៣ ឆ្នាំនេះតទៅ បងនឹងទៅ ។ ព្រះភរតៈទូល
សួរថា រហូតកាលត្រឹមប៉ុណ្ណោះ អ្នកណានឹងគ្រងរាជ-
សម្បត្តិ ។ ព្រះរាមត្រាស់ថា ពួកអ្នកចូរគ្រងរាជសម្បត្តិ
ចុះ ។ ព្រះភរតៈទូលថា ពួកខ្ញុំនឹងមិនគ្រងរាជសម្បត្តិ
ទេ ។ ព្រះរាមត្រាស់ថា បើយ៉ាងនោះ ទ្រនាប់ជើងទាំង
នេះ នឹងគ្រងរាជសម្បត្តិរហូតដល់បងទៅ ហើយទ្រង់
ដោះ**តិណបាទុកា** ( ទ្រនាប់ជើងដែលធ្វើដោយស្មៅ )
របស់ព្រះអង្គប្រទានឲ្យ ។ ក្សត្រទាំង ៣ ព្រះអង្គ
ទទួលទ្រនាប់ជើង ហើយថ្វាយបង្គំព្រះរាម ឡោមព័ទ្ធ
ដោយមហាជន ស្ដេចទៅកាន់នគរពារាណសី។

ទ្រង់ទាប់ដើងគ្រងរាជសម្បត្តិអស់ ៣ ឆ្នាំ ។ ពួកអាមាត្យ
នាំគ្នាតម្កល់តិណបាទុកា លើរាជបល្ល័ង្ក ហើយនាំគ្នា
កាត់ក្តី ។ បើកាត់ក្តីមិនល្អ ទ្រង់ទាប់ដើងរមែងខ្ទាំងខ្ទប់នូវ
គ្នានឹងគ្នា ដោយសញ្ញានេះ ត្រូវនាំគ្នាកាត់ក្តីសាជាថ្មី ។
ពេលដែលកាត់ក្តីល្អប្រពៃហើយ ទ្រង់ទាប់ដើងប្រាស
ចាកសំឡេង នឹងនៅស្ងៀម ។ ដោយកាលកន្លងទៅ ៣
ឆ្នាំ ព្រះរាមចេញពីព្រៃ ហើយទៅដល់នគរពារាណសី
បានចូលទៅកាន់ឧទ្យាន ។ ព្រះកុមារទាំងឡាយទ្រង់
ជ្រាបសេចក្តីដែលព្រះរាមស្តេចយាងមក មានពួក
អាមាត្យឡោមព័ទ្ធទៅកាន់ព្រះឧទ្យាន ទ្រង់ធ្វើព្រះ
នាងសីតាឲ្យជាអគ្គមហេសី ហើយធ្វើនូវការអភិសេក
សូម្បីដល់ក្សត្រទាំងពីរ ។ ព្រះមហាសត្វទ្រង់អភិសេក
យ៉ាងនេះហើយ ប្រថាប់លើរាជរថដែលគេប្រដាប់

តាក់តែងហើយ ស្តេចចូលកាន់ព្រះនគរដោយបរិវារដ៏ច្រើន ទ្រង់ប្រទក្សិណនគរ ហើយស្តេចឡើងកាន់ទីអាស្រ័យនៃចន្ទកប្រាសាទ តាំងតែពេលនោះមក ទ្រង់គ្រងរាជសម្បត្តិដោយធម៌ អស់ ១៦០០០ ឆ្នាំ ក្នុងវេលាអស់ព្រះជន្មាយុ ទ្រង់បានកើតក្នុងស្ថានសួគ៌ ។

អភិសម្ពុទ្ធគាថាសម្តែងសេចក្តីនោះថា ៖

**ទស វស្សសហស្សានិ, សដ្ឋិ វស្សសតានិ ច;**
**កម្ពុគីវោ មហាពាហុ, រាមោ រជ្ជមការយិ។**

ព្រះបាទរាម: មានព្រះសូរង្គ ដូចជារូបសំណាកមាស មានព្រះពាហុធំ បានសោយរាជ្យ អស់ ១៦ ០០០ ឆ្នាំ ។

# ជាតកាវសាន

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ ក្នុងវេលាចប់សច្ចធម៌ កុដុម្ពិកៈ បានតាំងនៅក្នុងសោតាបត្តិផល រួចទ្រង់ប្រជុំជាតកថា ៖

- តទា ទសរថមហារាជា សុទ្ធោទនមហារាជា អហោសិ ព្រះបាទទសរថមហារាជគ្រានោះ បានមកជាព្រះបាទសុទ្ធោទនមហារាជ
- មាតា មហាមាយាទេវី ព្រះមាតាបានមកជាព្រះនាងមហាមាយាទេវី

- សីតា រាហុលមាតា ព្រះនាងសីតាបាន មកជារាហុលមាតា
- ភរតោ អានន្ទោ ភរតៈបានមកជាអានន្ទ
- លក្ខណោ សារិបុត្តោ ព្រះលក្ខណ៍បាន មកជាសារីបុត្រ
- បរិសា ពុទ្ធបរិសា រាជបរិស័ទបានមកជា ពុទ្ធបរិស័ទ
- រាមបណ្ឌិតោ បន អហមេវ អហោសិំ ចំណែករាមបណ្ឌិតគឺតថាគតនេះឯង ។

ទសរថជាតក ចប់ ៕

( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឯកាទសក-និបាត ទសរថជាតក បិដកលេខ ៥៩ ទំព័រ ២២៩ )



សេចក្ដីពិតថា ជនទាំងឡាយណា ទាំង
ក្មេង ទាំងចាស់ ទាំងល្ងង់ ទាំងប្រាជ្ញ ទាំង
អ្នកមាន ទាំងអ្នកក្រ ជនទាំងអស់នោះ
សុទ្ធតែមានសេចក្ដីស្លាប់នៅខាងមុខ